### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

### សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម ឧត្តមសេនីយ៍ត្រី **ហាញ់ ចំរុង** នាយករងទីចាត់ការអភិវឌ្ឍន៍នៃអគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ ដែលបានឧបត្ថម្ភថវិកាចំនួន ១០.០០០ ដុល្លារ សំរាប់ចំណាយក្នុងការបំពាក់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យនៅទីតាំងមួយចំនួន ក្នុងខេត្តកំពង់ស្ពឺ និង ខេត្តកោះកុង ។

**មាត្រា២**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី អភិបាលខេត្តកំពង់ស្ពឺ និង ខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៧.សសរ

# សេចក្តីសម្រេច

# ស្តីពី

# ការបង្កើតគណៈកម្មការកសាងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ០៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២៣៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការកែតម្រូវមាត្រា ១ មាត្រា ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

-យោងតាមតម្រូវការចាំបាច់នៃការងារ

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការកសាងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានសមាសភាព ដូចតទៅ ÷

| | | |
|---|---|---|
| ១-ឯកឧត្តម **ញឹម វណ្ណដា** | ទេសរដ្ឋមន្ត្រី អនុប្រធានទី ១ គ.ជ.គ.ម | ប្រធាន |
| ២-ឯកឧត្តម **លី ធុជ** | ទេសរដ្ឋមន្ត្រី អនុប្រធានទី ២ គ.ជ.គ.ម | អនុប្រធាន |
| ៣-ឯកឧត្តម **ម៉ឹង សំផន** | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | អនុប្រធាន |
| ៤-ឯកឧត្តម **ពៅ សាមី** | អគ្គលេខាធិការ គ.ជ.គ.ម | អនុប្រធាន |
| ៥-ឯកឧត្តម **សំ សារិត** | រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៦-ឯកឧត្តម **ខាយ ឃុនហេង** | រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៧-ឯកឧត្តម **ប៊ុន ណារិទ្ធិ** | អគ្គលេខាធិការរង គ.ជ.គ.ម | សមាជិក |
| ៨-ឯកឧត្តម **គីម វឌ្ឍនា** | អគ្គលេខាធិការរង គ.ជ.គ.ម | សមាជិក |
| ៩-ឯកឧត្តម **នូ មុត** | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០-ឯកឧត្តម **ហ៊ូ តាំងអេង** | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ១១-ឯកឧត្តម **ប្រាក់ សារឿន** | ប្រធានក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ | សមាជិក |
| ១២-ឯកឧត្តម **វេជ្ជ តែ គុយស៊ាង** | អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ១៣-ឯកឧត្តម **ឈួន ដារ៉ា** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៤-ឯកឧត្តម **ឆា ដុប** | អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១៥-ឯកឧត្តម **គីម សុភ័ណ** | អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៦-ឯកឧត្តម **ជួប សុភក្តិ** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៧-ឯកឧត្តម **ឆៀង វណ្ណដារ៉ុង** | អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ១៨-ឯកឧត្តម **អៀម សារុំ** | អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ១៩-ឯកឧត្តម **ទ្រី ម៉េង** | អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ២០-ឯកឧត្តម **យាង សេង** | សមាជិកបំរុង ក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២១-ឯកឧត្តម **ផៃ សុខខេង** | អគ្គលេខាធិការរង ក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២២-ឯកឧត្តម **និត ហ៊ើល** | នាយកខុទ្ទកាល័យ គ.ជ.គ.ម | សមាជិក |
| ២៣-ឯកឧត្តម **រស់ សុវណ្ណ** | ទីប្រឹក្សា គ.ជ.គ.ម | សមាជិក |
| ២៤-ឯកឧត្តម **ឡាំ ហេងហួត** | ទីប្រឹក្សា គ.ជ.គ.ម | សមាជិក |
| ២៥-លោកស្រី **ជួង វឌ្ឍនី** | អគ្គនាយករង ក្រសួងកិច្ចការនារី | សមាជិក |
| ២៦-លោក **ហង្ស ប៊ុណ្ណាក់** | អគ្គនាយករង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២៧-លោក **ផាត់ ពៅស៊ាង** | មេធាវី | សមាជិក |
| ២៨-លោក បណ្ឌិត **សុខ សាលន់** | មេធាវី | សមាជិក |

| | | |
|---|---|---|
| ២៩-លោក **កៅ ម៉ុនហុង** | មេធាវី | សមាជិក |
| ៣០-លោក **អេង គីមលី** | តំណាង ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៣១-លោក **ឌុច សំអាង** | តំណាង កាកបាទក្រហមកម្ពុជា | សមាជិក ។ |

គណៈកម្មការកសាងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ មានភារកិច្ចដូចតទៅ ÷

-ធ្វើការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងដៃគូអភិវឌ្ឍន៍នានា លើព័ត៌មាន និងទិន្នន័យដែលពាក់ព័ន្ធ ដើម្បីឱ្យការកសាងសេចក្តីព្រាងច្បាប់មានមូលដ្ឋានគ្រប់គ្រាន់

-អញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ពន្ធ័ អាជ្ញាធរដែនដី ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ចូលរួមប្រជុំ សិក្ខាសាលាពិភាក្សាផ្តល់ទិន្នន័យចូលបន្ថែមលើសេចក្តីព្រាងច្បាប់

-ពិនិត្យ ពិចារណា និងសម្រេចយល់ព្រមលើសេចក្តីព្រាងច្បាប់ ដើម្បីដាក់ជូនកិច្ចប្រជុំអន្តរក្រសួងពិនិត្យ ផ្តល់យោបល់ មុនដាក់ឆ្លងកិច្ចប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី

-បូកសរុបធ្វើរបាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

**ប្រការ ២ :** ត្រូវបានបង្កើតក្រុមលេខាពិគ្រោះយោបល់ ជាជំនួយការដល់គណៈកម្មការកសាងសេចក្តីព្រាងច្បាប់ ដែលមានសមាសភាព ដូចតទៅ ÷

| | | |
|---|---|---|
| ១-ឯកឧត្តម **ពៅ សាមី** | អគ្គលេខាធិការ គ.ជ.គ.ម | ប្រធាន |
| ២-ឯកឧត្តម **ហ៊ូ តាំងអេង** | អនុរដ្ឋលេខាធិការក្រសួងផែនការ | អនុប្រធាន |
| ៣-ឯកឧត្តម **ង៉ែ សុខខេង** | អគ្គលេខាធិការរង ក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤-ឯកឧត្តម **ម៉ុន ណារិទ្ធិ** | អគ្គលេខាធិការរង គ.ជ.គ.ម | អនុប្រធាន |
| ៥-ឯកឧត្តម **គីម វឌ្ឍនា** | អគ្គលេខាធិការ គ.ជ.គ.ម | សមាជិក |
| ៦-ឯកឧត្តម **រស់ សុវណ្ណា** | ទីប្រឹក្សា គ.ជ.គ.ម | សមាជិក |
| ៧-ឯកឧត្តម **យ៉ាង សេង** | សមាជិកបំរុង ក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨-ឯកឧត្តម **ឡាំ ហេងហួត** | ទីប្រឹក្សា គ.ជ.គ.ម | សមាជិក |
| ៩-លោក **ផាត់ ពៅស៊ាង** | មេធាវី | សមាជិក |
| ១០-លោក បណ្ឌិត **សុខ សាលន់** | មេធាវី | សមាជិក |
| ១១-លោក **កៅ ម៉ុនហុង** | មេធាវី | សមាជិក |
| ១២-លោក ឧត្តមសេនីយ៍ **ខា លីស្រ៊ុន** | ជំនួយការ គ.ជ.គ.ម | សមាជិក |
| ១៣-លោក **ឃុន សុខា** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល | លេខាធិការ |
| ១៤-លោក **កែវ វី** | ជំនួយការ អនុប្រធានទី ១ | លេខាធិការ ។ |

ក្រុមលេខាពិគ្រោះយោបល់ មានភារកិច្ចដូចតទៅ ÷

-ប្រមូលព័ត៌មាន ឯកសាររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ សំរាប់ធ្វើជាមូលដ្ឋានក្នុងការកសាងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

-សិក្សាស្រាវជ្រាវ វិភាគ សំយោគ និងវាយតម្លៃនូវសកម្មភាពនានាដែលទាក់ទងនិងការងារគ្រប់គ្រងគ្រោះមហន្តរាយសំរាប់បញ្ចូលក្នុងខ្លឹមសារសេចក្តីព្រាងច្បាប់

-រៀបចំតាក់តែងសេចក្តីព្រាងច្បាប់ និងដាក់ឆ្លងគណៈកម្មការពិនិត្យ និងសម្រេច ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចចែងក្នុងប្រការ ១ និងប្រការ ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០១ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤ /១២៤ ចុះ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ ០៤ នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញ ព្រះរាជក្រមលេខ ៦២ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញ ព្រះរាជក្រមលេខ នស / រកម/ ០១៩៦/ ២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧

# សម្រេច

**ប្រការ១:** បង្កើតក្រុមការងារអន្តរក្រសួង ដែលមានឈ្មោះថា « **ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនទ្រព្យ** » ដែលមានសមាសភាពដូចខាងក្រោម :

- ឯកឧត្តម **ទី តាយី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន
- ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ជាអនុប្រធាន
- តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ២ រូប ជាសមាជិក
- តំណាងធនាគារជាតិ នៃកម្ពុជា ២ រូប ជាសមាជិក
- តំណាងនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ២ រូប ជាសមាជិក
- តំណាងនាយកដ្ឋានពន្ធដារ ១ រូប ជាសមាជិក
- តំណាងក្រុមប្រឹក្សាជាតិគណនេយ្យ ១ រូប ជាសមាជិក
- ប្រធានការិយាល័យគ្រប់គ្រងអចលនវត្ថុ ជាសមាជិក និងជាលេខាធិការ

**ប្រការ២:** ក្រុមការងារអន្តរក្រសួងមានភារកិច្ចដូចតទៅ:

- រៀបចំតាក់តែងគោលនយោបាយអភិវឌ្ឍ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ ។
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជូនរាជរដ្ឋាភិបាលអំពីការអភិវឌ្ឍន៍វិស័យអចលនវត្ថុ នៅព្រះរាជាណាចក្រកម្ពុជា ។
- ក្រុមការងារអន្តរក្រសួងអាចស្នើសុំរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បង្កើតក្រុមការងារតូចៗតាមការចាំបាច់ ។

**ប្រការ៣:** បន្ថែមលើមុខងារ និងភារកិច្ចដូចមានចែងក្នុងប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តិទៅ នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុ ទទួលតួនាទីជាលេខាធិការដ្ឋានអោយក្រុមការងារអន្តរក្រសួង ។

**ប្រការ៤:** សមាជិកទាំងអស់ត្រូវចូលរួមប្រជុំទៅតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៥:** ក្នុងករណីប្រធានក្រុមការងារអវត្តមាន អនុប្រធានក្រុមការងារនេះធ្វើជាប្រធានស្តីទី ។

**ប្រការ៦:** ធនធាន និងថវិកាសំរាប់ចំណាយផ្សេងៗរបស់ក្រុមការងារនេះ ត្រូវបានផ្គត់ផ្គង់ដោយថវិការបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ/និងដោយចំណូលការប្រាក់ពីគណនីអាណត្តិ ព្យាបាលភាព ។

**ប្រការ៧:** ប្រធានក្រុមការងារត្រូវធ្វើរបាយការណ៍ប្រចាំឆមាសអំពីការអភិវឌ្ឍន៍វិស័យអចលនវត្ថុនៅព្រះរាជាណាចក្រកម្ពុជា ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយចំលងជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងធនាគារជាតិនៃកម្ពុជា ។

**ប្រការ៨:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨*

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

**<u>ចំលងជូន:</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  « ដើម្បីជូនជ្រាប »
- ដូចមានក្នុងប្រការ ៨
  « ដើម្បីអនុវត្ត »
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខៈ ១០៥ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ ១.-**

ទំនិញនាំចូលដោយលើកលែងពន្ធ និងអាករនាំចូលក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក កថាខណ្ឌទី ១ មាត្រា ២៦ នៃច្បាប់ស្តីពីគយ សម្រាប់បេសកកម្មការទូត ឬបេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការ

បច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងទៀត ដើម្បីប្រើប្រាស់ក្នុងការិយកិច្ចនៃមុខងារជាផ្លូវការរបស់ខ្លួន និងបុគ្គលិករបស់អង្គការទាំងនេះ ត្រូវនាំចេញទៅវិញបន្ទាប់ពីបញ្ចប់បេសកម្មរបស់ខ្លួន ។

ទំនិញទាំងនេះព្រមទាំងទំនិញផ្សេងទៀតក្រោមបញ្ញត្តិកថាខណ្ឌទី ១ មាត្រា ២៦ នៃច្បាប់ស្តីពីគយ មិនត្រូវបានអនុញ្ញាតឱ្យលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេងពីគម្បដ្ឋានដែលបានអនុគ្រោះ ឬបោះបង់ចោលដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយឡើយ ។

**ប្រការ ២.-**

ទំនិញនាំចូលដោយលើកលែងជាភាគនៃពន្ធ និងអាករនាំចូល ក្រោមបញ្ញត្តិមាត្រា ២៧ នៃច្បាប់ស្តីពីគយ មិនត្រូវបានអនុញ្ញាតឱ្យលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេងពីគម្បដ្ឋានដែលបានអនុគ្រោះ ឬបោះបង់ចោលដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយឡើយ ។

**ប្រការ ៣.-**

អង្គការ ឬបុគ្គលនានាដែលមានបំណងលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេងពីគម្បដ្ឋានដែលបានអនុគ្រោះ ឬបោះបង់ចោលទំនិញដែលបាននាំចូលដោយលើកលែង ឬលើកលែងជាភាគនូវពន្ធ និងអាករនាំចូលត្រូវស្នើសុំការអនុញ្ញាតជាមុនពីរដ្ឋបាលគយស្របតាមនីតិវិធីដូចខាងក្រោម ៖

ក. ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតមករដ្ឋបាលគយ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីរបៀបនៃការប្តូរគម្បដ្ឋាន ឬការប្តូរកម្មសិទ្ធលើទំនិញនេះ ។ ច្បាប់ចម្លងនៃពាក្យស្នើសុំនេះត្រូវផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រាប់ទំនិញដែលនាំចូលក្រោមបញ្ញត្តិកថាខណ្ឌទី ១ ប្រការ ១ នៃប្រកាសនេះ ។

ខ. ពាក្យស្នើសុំត្រូវអមដោយបញ្ជីទំនិញ និងឯកសារនាំចូលព្រមទាំងឯកសារផ្សេងទៀតប្រសិនបើមាន ។ ទំនិញពុំត្រូវបានអនុញ្ញាតឱ្យលក់ ផ្ទេរ ឬបង្វែរមុនពេលទទួលបានការអនុញ្ញាតពីរដ្ឋបាលគយឡើយ ។

គ. កម្មសិទ្ធករថ្មីត្រូវទទួលខុសត្រូវលើការបង់ពន្ធ និងអាករជូនរដ្ឋបាលគយតាមនីតិវិធីគយជាធរមាន ។ ទំនិញពុំអាចត្រូវបានប្រគល់ជូនកម្មសិទ្ធករថ្មីដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយ និងមុនពេលបង់ពន្ធ និងអាករដែលជាប់ ឬទទួលបានការលើកលែងពន្ធជាថ្មីពីស្ថាប័នមានសមត្ថកិច្ច ។

ឃ. រដ្ឋបាលគយត្រូវគិតគូរពីលក្ខខណ្ឌជាក់ស្តែង និងសភាពនៃទំនិញទាំងនោះនាពេលប្រគល់ទទួល និងអាចកែសម្រួលតម្លៃគិតពន្ធគយតាមនេះ ។

**ប្រការ ៤.-**

ទំនិញដែលមានប្រភពក្នុងដែនគយ ឬដែលបាននាំចូលដោយបង់ពន្ធ និងអាកររួច ឬដែលនាំចូលត្រឡប់មកវិញពីបរទេសដោយពុំមានបន្ថែមតម្លៃ ត្រូវបានអនុញ្ញាតឱ្យលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់ ឬបោះបង់ចោលដោយពុំចាំបាច់មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយឡើយ ។

**ប្រការ ៥.-**

អង្គការ ឬបុគ្គលនានាដែលមានបំណងបោះបង់ចោលទំនិញដែលបាននាំចូលដោយលើកលែងពន្ធ និងអាករនាំចូល ត្រូវស្នើសុំការអនុញ្ញាតជាមុនពីរដ្ឋបាលគយ ។ ការស្នើសុំត្រូវអមដោយបញ្ជីទំនិញ និងឯកសារនាំចូលព្រមទាំងឯកសារពាក់ព័ន្ធផ្សេងទៀត ។

ការបោះបង់ចោលទំនិញអាចធ្វើឡើងតែក្រោយពេលមានការអនុញ្ញាតពីរដ្ឋបាលគយ ។ រដ្ឋបាលគយអាចឃ្លាំមើលការបោះបង់ចោល ឬការបំផ្លាញទំនិញទាំងនេះ ។

**ប្រការ ៦.-**

ទីចាត់ការគយ និងរដ្ឋាករមានកាតព្វកិច្ចសហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវបញ្ញត្តិប្រការ ១ និងប្រការ ៣ នៃប្រកាសនេះ ។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៨
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ២០២ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស
# ស្តីពី
# សន្និធិគយបណ្តោះអាសន្ន

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១**.-

បង្កើតសន្និធិគយបណ្តោះអាសន្នលើទំនិញនាំចូល និងនាំចេញ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គយ នៅតាមទីកន្លែងដែលមានការអនុញ្ញាត រង់ចាំបំពេញទម្រង់ការគយ ដោយអនុលោមតាមបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ស្តីពីគយ ។ ទីកន្លែងសន្និធិគយបណ្តោះអាសន្នរួមមាន បណ្តោកណ្តោគារ (ឃ្លាំង) ដែលត្រូវបញ្ចេញទំនិញពីគយដែលស្ថិតក្រោមការគ្រប់គ្រងរបស់គយ ។

**ប្រការ ២.-**

លក្ខខណ្ឌនានាពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណសម្រាប់ប្រតិបត្តិការទីកន្លែងសន្និធិគយបណ្តោះអាសន្ន មានដូចខាងក្រោម ៖

១. អាជ្ញាប័ណ្ណសម្រាប់ប្រតិបត្តិការទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អាជ្ញាប័ណ្ណនេះនឹងកំណត់នូវលក្ខខណ្ឌសម្រាប់ម្ចាស់កម្មសិទ្ធ និងប្រតិបត្តិករ រាប់បញ្ចូលទាំងទីតាំងសំណង់ គម្រោងអាគារ កម្រិតនិមុត្តិជានា ព្រមទាំងនីតិវិធីសម្រាប់ចាត់ចែងគ្រប់គ្រង និងត្រួតពិនិត្យទំនិញ ។

២. បុគ្គលដែលមានបំណងស្នើសុំអាជ្ញាប័ណ្ណ ត្រូវដាក់ពាក្យស្នើសុំទៅនាយកទីចាត់ការគយ និងរដ្ឋាករ តាមទម្រង់ដែលបានកំណត់ដោយភ្ជាប់ទៅជាមួយនូវប្លង់នៃសំណង់ និងទីតាំងនៃទីកន្លែងសន្និធិគយបណ្តោះអាសន្ន ដែលស្នើសុំ ។

៣. អាជ្ញាប័ណ្ណអាចនឹងត្រូវចេញជូនបានប្រសិនបើ ៖

- អ្នកស្នើសុំមានលក្ខណៈសម្បត្តិល្អ

- អ្នកស្នើសុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់ដល់ការសាងសង់ទីកន្លែង បំពាក់បរិក្ខារ ដល់បុគ្គលិក និងសេវាកម្មចាំបាច់នានា នៃកិច្ចប្រតិបត្តិការ

- ទីតាំងស្នើសុំសម្រាប់សាងសង់ទីកន្លែងសន្និធិគយបណ្តោះអាសន្នត្រូវស្ថិតក្នុងចម្ងាយសមស្របមួយពីផ្លូវគមនាគមន៍សំខាន់ និងពីការិយាល័យគយ និងត្រូវមានទំហំផ្ទៃក្រឡាគ្រប់គ្រាន់សម្រាប់សន្និធិទំនិញនាំចេញ និងនាំចូល ។ គ្រោងឆ្អឹងអាគារនៃទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវបង្កឲ្យមានភាពងាយស្រួលសម្រាប់ប្រតិបត្តិការ

- រដ្ឋបាលគយអាចគ្រប់គ្រង និងត្រួតពិនិត្យទម្រង់ការគយ លើទំនិញដែលសន្និធិក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ដែលបានស្នើសុំ ។

៤. អាជ្ញាប័ណ្ណអាចត្រូវបានកែប្រែដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគោលបំណង ៖

- ផ្លាស់ប្ដូរនូវកម្រិតកំណត់ ឬលក្ខខណ្ឌនានាក្នុងអាជ្ញាប័ណ្ណពាក់ព័ន្ធនឹងទំនិញដែលអាចបញ្ចូលក្នុងទីកន្លែងសន្និធិគយបណ្ដោះអាសន្ន ឬដើម្បីបញ្ជាក់បន្ថែមនូវកម្រិតកំណត់ និងលក្ខខណ្ឌនេះ

- ផ្លាស់ប្ដូរនាមករណ៍របស់បុគ្គលទទួលអាជ្ញាប័ណ្ណប្រសិនបើនាមករណ៍នោះត្រូវបានផ្លាស់ប្ដូរ ។

៥. អាជ្ញាប័ណ្ណអាចនឹងត្រូវបានលុបចោលដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រសិនបើបុគ្គលដែលទទួលបានអាជ្ញាប័ណ្ណ ៖

- លែងជាម្ចាស់ឬជាអ្នកជួលទីកន្លែងសន្និធិគយបណ្ដោះអាសន្ន នោះ

- ស្នើសុំលុបអាជ្ញាប័ណ្ណជាលាយល័ក្ខអក្សរទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ត្រូវបានក្ស័យធន ។

៦. អាជ្ញាប័ណ្ណអាចនឹងត្រូវបានលុបចោលដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រសិនបើបុគ្គលដែលទទួលបានអាជ្ញាប័ណ្ណ ៖

- ជាកម្មវត្ថុនៃភាពដែលមិនអាចសងបំណុលរបស់ខ្លួនបាន

- ខកខាន មិនបានអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងការនាំចូល និងការនាំចេញទំនិញ

- បានប្រព្រឹត្តិអំពើមិនត្រឹមត្រូវ ក្នុងធុរកិច្ចរបស់ខ្លួន ជាមួយនឹង អាជ្ញាធរមានសមត្ថកិច្ច ដើងសារគយ អ្នកនាំចូល អ្នកនាំចេញ និងអ្នកដឹកជញ្ជូន

- គ្មានសមត្ថភាពដើម្បីធ្វើប្រតិបត្តិការទីកន្លែងសន្និធិគយបណ្ដោះអាសន្ន ។

៧. បុគ្គលដែលទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការទីកន្លែងសន្និធិគយបណ្ដោះអាសន្នត្រូវបង់កម្រៃអាជ្ញាប័ណ្ណប្រចាំឆ្នាំចំនួន ម្ភៃលាន (២០.០០០.០០០ ) រៀល ជូនទីចាត់ការគយ និងរដ្ឋាករដើម្បីបង់ចូលថវិការដ្ឋ ។

**ប្រការ ៣.-**

ប្រតិបត្តិករទីកន្លែងសន្និធិគយបណ្ដោះអាសន្នត្រូវតែតម្កល់ប្រាក់ធានានៅទីចាត់ការគយ និងរដ្ឋាករតាមចំនួនគ្រប់គ្រាន់សម្រាប់ធានានូវការបង់ពន្ធ អាករ

កម្រៃ និងបន្ទុកផ្សេងៗលើទំនិញដែលផ្ទុកក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ។ ទម្រង់នៃនិមុត្តិជានាត្រូវអនុលោមតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ស្តីពីគយ និង បទបញ្ញត្តិពាក់ព័ន្ធ ។

**ប្រការ ៤**.-

រាល់ចំណាយពាក់ព័ន្ធទីកន្លែងសន្និធិគយបណ្តោះអាសន្ន រាប់បញ្ចូល ទាំងថ្លៃថែទាំ និងជួសជុលជាបន្ទុករបស់ម្ចាស់កម្មសិទ្ធ ឬប្រតិបត្តិករ ។ ម្ចាស់កម្មសិទ្ធ ឬប្រតិបត្តិករទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវជានាដោះស្រាយជូននូវ ទីកន្លែងសមរម្យ និងគ្រប់គ្រាន់ ដោយមិនយកកម្រៃជូនមន្ត្រីគយ ដើម្បីបំពេញ ការងារ ។

**ប្រការ ៥**.-

ប្រតិបត្តិករទីកន្លែងសន្និធិគយបណ្តោះអាសន្ន ជាអ្នកទទួលខុសត្រូវ ចំពោះពន្ធ អាករ និងកម្រៃផ្សេងៗ ដោយអនុលោមតាមបញ្ញត្តិមាត្រា ៣៥ នៃច្បាប់ ស្តីពីគយ ។

ចំពោះទំនិញដែលខូច ឬដែលបាក់បែកដោយគ្រោះថ្នាក់ ឬករណី ប្រធានស័ក្តិ ក្នុងរយៈពេលសន្និធិគយជាបណ្តោះអាសន្ន ដែលមន្ត្រីគយទទួលស្គាល់ នឹងត្រូវគិតពន្ធ និងអាករ លើមូលដ្ឋាននៃសភាពទំនិញនោះ នាពេលយកចេញពី ទីកន្លែងសន្និធិគយបណ្តោះអាសន្ន ។

**ប្រការ ៦**.-

ទំនិញដែលដាក់ក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ជាកម្មវត្ថុនៃការ ត្រួតពិនិត្យដោយគយ និងត្រូវសន្និធិ ដោយអនុលោមតាមនីតិវិធីដែលបានកំណត់។

ទំនិញត្រូវបានដាក់ក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ក្នុងគោលបំណង ផលដូចខាងក្រោម ៖

- រង់ចាំឯកសារចាំបាច់នានា សម្រាប់បំពេញទម្រង់ការគយ
- រង់ចាំផ្ទេរចេញ ឬបំបែកទំនិញចេញពីកុងតេន័រ ✓

- សម្រាប់ត្រួតពិនិត្យទំនិញ
- រង់ចាំការបំពេញចម្លងការពាណិជ្ជកម្ម ។

ទំនិញដែលដាក់ក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវបានបញ្ចេញពីគយជាបន្ទាន់ ក្រោយពេលដាក់ប្រតិវេទន៍គយដើម្បីបញ្ចេញទំនិញពីគយ ឬដើម្បីដឹកជញ្ជូនឆ្លងកាត់ និងក្រោយពេលបំពេញទម្រង់ការគយរួច ។

**ប្រការ ៧.-**

ការដាក់ទំនិញចូលទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវបានផ្អាកនូវការបង់ពន្ធ អាករ និងកម្រៃនានា ព្រមទាំងតម្រូវការនៃការដាក់ប្រតិវេទន៍គយ និងឯកសារចាំបាច់នានា តាមនីតិវិធីបញ្ចេញទំនិញពីគយ ។

**ប្រការ ៨ .-**

ទំនិញទាំងឡាយអាចដាក់ចូលទីកន្លែងសន្និធិគយបណ្តោះអាសន្ន លើកលែងតែ ៖

- ទំនិញហាមឃាត់ដាច់ខាតដល់ការនាំចេញ និងនាំចូល
- ទំនិញដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់មនុស្ស និងដល់ទំនិញដទៃទៀត ឬដែលតម្រូវឲ្យមានទីកន្លែងសន្និធិដោយឡែក ដែលបំពាក់នូវបរិក្ខាពិសេស សម្រាប់សន្និធិទំនិញប្រភេទនេះ ។

**ប្រការ ៩.-**

ការដាក់ទំនិញចូលទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវអនុវត្តតាមនីតិវិធីដូចតទៅ ៖

១. ទំនិញទាំងឡាយចាំបាច់ត្រូវបង្ហាញដល់មន្ត្រីគយ មុននឹងដាក់ទំនិញចូល ។

២.ត្រូវតម្កល់ប្រតិវេទន៍បំពេញដែលមានចុះហត្ថលេខាដោយម្ចាស់ទីកន្លែងសន្និធិគយបណ្តោះអាសន្ន មុននឹងដាក់ទំនិញចូល ។

៣. ប្រតិវេទន៍បំពេញដែលនឹងកំណត់ដោយនាយកទីចាត់ការគយនិងរដ្ឋាករត្រូវមានចុះ៖

- លេខ និងកាលបរិច្ឆេទចុះបញ្ជិកា
- បរិមាណ ប្រភេទ សញ្ញា និងលេខកញ្ចប់ការ
- បរិយាយមុខទំនិញ
- ទម្ងន់ទាំងសម្បក
- នាមរបស់អ្នកនាំចេញ ឬអ្នកនាំចូល
- ប្រទេសផ្គត់ផ្គង់ ឬនាំចេញ និងប្រទេសនាំចូល
- របៀប និងមធ្យោបាយដឹកជញ្ជូន
- ឯកសារយោងដែលចង្អុលបង្ហាញអំពី ប្រភេទ លេខ កាលបរិច្ឆេទ នៃឯកសារដឹកជញ្ជូននាពេលនាំចូល ឬឯកសារផ្សេងទៀតនាពេលនាំចេញ ។ ច្បាប់ចម្លងនៃឯកសារទាំងនេះត្រូវភ្ជាប់ជាមួយប្រតិវេទន៍បំពេញនៅពេលបង្ហាញជូនមន្ត្រីគយ ។

**ប្រការ ១០.-**

កិច្ចបញ្ជិកាប្រតិវេទន៍បំពេញ ត្រូវស្ថិតក្រោមលក្ខខណ្ឌដូចតទៅ៖

១. ប្រតិបត្តិករទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវចុះបញ្ជីប្រតិវេទន៍បំពេញដែលមានចុះបញ្ជិកាគយរួចពីមន្ត្រីគយទៅក្នុងបញ្ជីសន្និធិគយបណ្តោះអាសន្ន នៅពេលដែលទំនិញត្រូវបានដាក់ក្នុងសន្និធិគយបណ្តោះអាសន្ន ។

២. បញ្ជីមួយត្រូវបានបង្កើតសម្រាប់ឃ្លាំងនីមួយៗ ឬទីលាននីមួយៗ នៃសន្និធិគយបណ្តោះអាសន្ន បញ្ជីនេះហៅថា បញ្ជីសន្និធិគយបណ្តោះអាសន្ន ។ បញ្ជីនេះត្រូវមានចុះសូចនាដូចមានចែងក្នុងបញ្ញត្តិកថាខ័ណ្ឌ ៣ ប្រការ ៩ នៃប្រកាសនេះ និងត្រូវចុះបញ្ជាក់ផងដែរនូវទីតាំងដោយឡែក របស់ទំនិញទាំងឡាយក្នុងសន្និធិគយបណ្តោះអាសន្ន ។

៣.ទម្រង់នៃបញ្ជីសន្និធិគយបណ្តោះអាសន្ននឹងត្រូវកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ ។

៤. បញ្ជីដាច់ដោយឡែកពីគ្នាត្រូវបានបង្កើតសម្រាប់ប្រតិបត្តិនាំចូល និង សម្រាប់ប្រតិបត្តិនាំចេញ ។

៥. លេខ និងកាលបរិច្ឆេទនៃការចុះបញ្ជិកាគយ ត្រូវធ្វើនៅលើឯកសារ ដែលភ្ជាប់នឹងប្រតិវេទន៍បំពេញ ។

៦. ក្រោយពេលបានបំពេញទម្រង់ការគយដូចរៀបរាប់ខាងលើរួចហើយ ទើបការត្រួតពិនិត្យបំពេញដោយគយរួមមាន ការរាប់ និងការផ្ទៀងផ្ទាត់អត្តសញ្ញាណ នៃកណ្ឌិកាអាចត្រូវអនុវត្ត ។

**ប្រការ ១១.-**

នៅក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ដោយមានការអនុញ្ញាតជាមុនពីគយ ប្រតិបត្តិករអាចធ្វើសហត្ថកម្មនានាលើទំនិញដូចខាងក្រោម ៖

- ការថ្លឹង ការពិនិត្យជាមុន និងការរៀបចំទុកដាក់តាមប្រភេទទំនិញ
- ការដកគម្រូទំនិញ
- ការពិនិត្យកត់ត្រា ពីការបែកបាក់ ការខូចខាត និងការជ្រើសរើសទំនិញខូចខាត
- ការជួសជុល ឬប្តូរសម្បកវេចខ្ចប់ក្នុងករណីចាំបាច់
- ការវេចខ្ចប់ជាថ្មី និងគ្រប់សហត្ថកម្មទាំងឡាយ សម្រាប់ធ្វើឲ្យទំនិញមានភាពល្អឡើងវិញ ដោយមិនប្តូរលក្ខណៈនៃទំនិញ
- ប្រតិបត្តិការទាំងឡាយក្នុងគោលបំណងថែរក្សាទំនិញ ដូចជា ការបោសសម្អាតធូលី ការជូតជាដើម
- ការបិទផ្លាក ឬសញ្ញាសម្គាល់ សម្រាប់គោលបំណង ដឹកជញ្ជូនទំនិញបន្តទៀត ។

**ប្រការ ១២.-**

កំណត់រយៈពេលសំចតនៃទំនិញក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន គិតពីថ្ងៃចុះបញ្ជិកាគយលើប្រតិវេទន៍បំពេញ ដូចតទៅ ៖

- សាមសិប (៣០) ថ្ងៃសម្រាប់ទីកន្លែងសន្និធិគយបណ្តោះអាសន្នតាមអាកាសយានដ្ឋាន

- សែសិបប្រាំ(៤៥) ថ្ងៃ សម្រាប់ទីកន្លែងសន្និធិគយបណ្តោះអាសន្នដែលមានទីតាំងស្ថិតនៅក្រៅអាកាសយានដ្ឋាន

រយៈពេលសំចតនេះ អាចត្រូវបានពន្យារពេលដោយ នាយកទីចាត់ការគយ និងរដ្ឋាករ សម្រាប់រយៈពេលមិនលើសពីរយៈពេលដូចមានចែងក្នុងវាក្យខណ្ឌខាងលើនៃប្រការនេះ ។

**ប្រការ ១៣.-**

ផុតរយៈពេលដូចបានកំណត់ក្នុងប្រការ ១២ ខាងលើ ទំនិញទាំងឡាយត្រូវបានដាក់ជាស្វ័យប្រវត្តិទៅក្នុងនិក្ខិត្តភ័ណ្ឌគយ កាលបើទំនិញទាំងនោះពុំបានធ្វើប្រតិវេទន៍គយ ។ ក្នុងរយៈពេលដែលទំនិញត្រូវបានដាក់ក្នុងនិក្ខិត្តភ័ណ្ឌគយម្ចាស់ទំនិញត្រូវបង់កម្រៃ ០,១០ ភាគរយ លើតម្លៃគិតពន្ធគយ ក្នុងមួយថ្ងៃ ជូនទីចាត់ការគយ និងរដ្ឋាករ ។ កម្រៃនេះ ត្រូវកត់ត្រាចូលក្នុងប្រតិវេទន៍គយ និងបង់ចូលថវិការដ្ឋ ។ ទំនិញទាំងឡាយដែលត្រូវតម្កល់ជានិក្ខិត្តភ័ណ្ឌគយត្រូវកត់ត្រាក្នុងបញ្ជីពិសេស ។

**ប្រការ ១៤.-**

ទំនិញទាំងឡាយ ដែលពុំបានបំពេញបែបបទបញ្ចេញទំនិញពីគយ ពីទីកន្លែងសន្និធិគយបណ្តោះអាសន្នក្នុងរយៈពេល បី ( ៣ ) ខែ គិតពីថ្ងៃកត់ត្រាចូលក្នុងបញ្ជីនៃនិក្ខិត្តភ័ណ្ឌគយ ត្រូវបានចាត់ទុកថាជា ទំនិញគ្មានការទាមទារ និងត្រូវបានដាក់ក្រោមបញ្ញត្តិមាត្រា ៥៤ និងមាត្រា ៥៥ នៃច្បាប់ស្តីពីគយ ។

ចំពោះទំនិញទាំងឡាយ ដែលឆាប់ខូច ឬលំបាករក្សាទុក អាចត្រូវបានលក់ជាបន្ទាន់ ដោយមានការអនុញ្ញាតជាមុន ពីនាយកទីចាត់ការគយ និងរដ្ឋាករ ។ ចំពោះទំនិញដែលមានតម្លៃតិចជាង ប្រាំរយពាន់ (៥០០.០០០) រៀល ត្រូវបានចាត់ទុកថា ម្ចាស់បានបោះបង់ចោល ហើយរដ្ឋបាលគយអាចដាក់លក់ឡាយឡុង ឬធ្វើជាអំណោយដល់មន្ទីរពេទ្យ សង្គហដ្ឋាន ឬគ្រឹះស្ថានសប្បុរសធម៌ឯទៀតៗ ។

**ប្រការ ១៥.-**

ទំនិញទាំងឡាយដែលបាននាំចូល មុនពេលដែលប្រកាសនេះចូលជាធរមាន ហើយកំពុងស្ថិតនៅក្នុងទឹកដែនសន្និធិគយបណ្តោះអាសន្ន ក៏ជាកម្មវត្ថុនៃការអនុវត្ត តាមបញ្ញត្តិនៃប្រកាសនេះដែរ ។

**ប្រការ ១៦.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៧ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជូនជ្រាប "
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ១៧
- សភាពាណិជ្ជកម្មកម្ពុជា
" ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត "
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ១០៧.....សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការរាយការណ៍ ការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនទំនិញនាំចេញ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ ១.-**

ទំនិញគ្រប់ប្រភេទដែលនាំចេញ ត្រូវរាយការណ៍នៅការិយាល័យគយ ឬទីកន្លែងណាមួយតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ ស្របតាមបញ្ញត្តិមាត្រា ១៦ នៃច្បាប់ស្តីពីគយ ។

**ប្រការ ២.-**

ប្រតិវេទន៍គយនាំចេញត្រូវបំពេញដោយប្រតិវេទករ ស្របតាមបញ្ញត្តិនៃប្រកាសស្តីពីបញ្ញត្តិ និងនីតិវិធីប្រតិវេទន៍គយ ។

ឯកសារដែលភ្ជាប់ជាមួយប្រតិវេទន៍គយនាំចេញរួមមាន ៖

- វិក័យប័ត្រ និងបញ្ជីវេចខ្ចប់ទំនិញ
- លិខិតអនុញ្ញាតរបស់រដ្ឋបាលគយ និងលិខិតអនុញ្ញាតរបស់អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ប្រសិនបើមានការតម្រូវ ។

ប្រតិវេទន៍គយនាំចេញ អាចត្រូវដាក់ជូនរដ្ឋបាលគយមុនពេលទំនិញមកដល់ការិយាល័យគយ ដែលត្រូវធ្វើការនាំចេញ ប្រសិនបើមានការអនុញ្ញាតជាមុនពីរដ្ឋបាលគយ ។

**ប្រការ ៣ -**

នាយកទីចាត់ការគយ និងរដ្ឋាករអាចអនុញ្ញាតឲ្យទំនិញមួយចំនួនត្រូវបានធ្វើការប្រកាសក្នុងទម្រង់ដោយឡែកពីប្រតិវេទន៍គយនាំចេញ ។ ការអនុញ្ញាតនេះ អាចត្រូវបានផ្តល់សម្រាប់ ៖

- ទំនិញដែលមានតម្លៃទាបជាងតម្លៃអប្បបរមាមួយ ដែលកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ
- ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ដែលនាំចេញដោយឯកបុគ្គល ។

**ប្រការ ៤.-**

នៅពេលដែលអ្នកនាំចេញ ឬអ្នកតំណាងធ្វើការស្នើសុំជាលាយល័ក្ខអក្សរ រដ្ឋបាលគយ អាចអនុញ្ញាតឲ្យធ្វើការបំពេញបែបបទបញ្ចេញទំនិញពីគយនៅកន្លែងផ្សេងពីការិយាល័យគយដែលបានកំណត់ដូចជា ទីកន្លែងដែលផលិត ឬកែច្នៃទំនិញដើម្បីនាំចេញ ឬនៅតាមកណ្តាគារនានា ក្នុងគោលបំណងធានានូវសុវត្ថិភាព និងដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្មស្របច្បាប់ ។

ទំនិញដែលអាចទទួលបានការអនុញ្ញាតដោយរដ្ឋបាលគយ ឲ្យបំពេញបែបបទបញ្ចេញទំនិញពីគយនៅទីកន្លែងផ្សេងពីការិយាល័យគយដែលបានកំណត់ មានដូចខាងក្រោម ៖

- ផលិតផលប្រកបដោយគ្រោះថ្នាក់ ទំនិញងាយឆេះ ទំនិញងាយផ្ទុះ និងទំនិញឆាប់ខូច ដែលតម្រូវឲ្យមានរបៀបថែរក្សា និង[illegible]ជាពិសេស
- ផលិតផលកសិកម្ម
- ផលិតផលកែច្នៃសម្រេច ឬពាក់កណ្តាលសម្រេចធ្វើពីឈើ
- ជ័រកៅស៊ូគ្រប់ប្រភេទ

- ផលិតផលជលផលដែលតម្រូវឲ្យមានការផ្ទុកក្នុងល័ក្ខខ័ណ្ឌពិសេស
- ផលិតផលសម្រាប់នាំចេញ ដែលផលិតដោយក្រុមហ៊ុនវិនិយោគ ស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- ទំនិញផ្សេងទៀត តាមការសម្រេចរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ៥.-**

ទំនិញនាំចេញទាំងអស់ ទោះជាជាប់ ឬមិនជាប់អាករក្តី រួមទាំងមធ្យោបាយដឹកជញ្ជូនទំនិញចេញពីដែនគយ ជាកម្មវត្ថុនៃការត្រួតពិនិត្យគយ ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

**ប្រការ ៦.-**

នៅពេលមានការតម្រូវពីមន្ត្រីគយមានសមត្ថកិច្ច ប្រតិវេទករត្រូវផ្តល់នូវគម្រូនៃទំនិញនាំចេញ សម្រាប់សំណូមពរនៃការផ្ទៀងផ្ទាត់លើដើមកំណើត លក្ខណៈ ការចាត់ថ្នាក់តាមតារាងពន្ធគយ ឬតម្លៃគិតអាករ ។ នាយកទីចាត់ការគយ និងរដ្ឋាករអាចអនុញ្ញាតឲ្យមានការលើកលែងការផ្តល់ទំនិញគម្រូតាមការតម្រូវខាងលើនេះ ។

**ប្រការ ៧.-**

រាល់មធ្យោបាយដឹកជញ្ជូន ដែលចាកចេញពីដែនគយនៃព្រះរាជាណាចក្រកម្ពុជា ទោះបីមានផ្ទុក ឬពុំមានផ្ទុកនូវទំនិញនាំចេញក្តី ត្រូវតែបំពេញទម្រង់បែបបទគយ ដោយត្រូវដាក់ជូនរដ្ឋបាលគយនូវប្រតិវេទន៍គយនាំចេញ និងឯកសារភ្ជាប់ដូចជា ៖

- និវេទនប័ណ្ណ
- អញ្ញត្តិប័ណ្ណទំនិញ
- ឈ្មោះអ្នកទទួលខុសត្រូវលើមធ្យោបាយដឹកជញ្ជូន ។

បន្ទាប់ពីទម្រង់បែបបទគយត្រូវបានបំពេញរួច រដ្ឋបាលគយត្រូវអនុញ្ញាតឲ្យយកទំនិញទាំងអស់ដែលត្រូវនាំចេញ ដើម្បីនាំចេញពីព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង/

ហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**<u>ចម្លងជូន</u> ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី
  តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៩
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ១០៥ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស
# ស្តីពី
# ការបង្វិលសងវិញនូវពន្ធ និង អាករគយ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ ១.-**

អនុញ្ញាតឲ្យទីចាត់ការគយ និងរដ្ឋាករធ្វើការបង្វិលសងវិញ ទាំងស្រុង ឬ ភាគខ្លះនូវពន្ធ និងអាករនាំចូល ព្រមទាំងទឹកប្រាក់ផ្សេងៗទៀតដែលបានបង់រួច ចំពោះ ៖

១. ការបង់លើសដោយប្រការណាមួយ រាប់បញ្ចូលទាំងករណីដែលបណ្ដាលមកពីការភ័ន្តច្រឡំរដ្ឋបាលផង ។

២. ទំនិញនាំចូល ដែលនៅមុនពេលអនុញ្ញាតឲ្យយកចេញពីគយត្រូវពិនិត្យឃើញថា តិចជាង បែកបាក់ ខូចខាត គុណភាពទាប និងទំនិញនាំចេញទៅវិញ ឬបំផ្លាញចោលក្រោមការគ្រប់គ្រងឃ្លាំមើលរបស់គយ ទោះបីនៅក្រោយពេលអនុញ្ញាតឲ្យយកចេញពីគយរួចហើយក៏ដោយ ឬក្នុងករណីមានការផ្លាស់ប្ដូររបបគយក្តី ។

៣. ការបង់លើស ដែលបានរកឃើញ តាមរយៈសេចក្ដីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកដោះស្រាយការតវ៉ា ដូចមានចែងក្នុងបញ្ញត្តិមាត្រា ២៤ នៃច្បាប់ស្ដីពីគយ ឬដោយតុលាការមានសមត្ថកិច្ច ។ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកដោះស្រាយការតវ៉ា រួមមាន នាយកទីចាត់ការគយ និងរដ្ឋាករ ជាអាជ្ញាធរថ្នាក់ទី មួយ និងគណៈកម្មការតាពព័ន្ធគយ ជាអាជ្ញាធរថ្នាក់ទី ពីរ ។

**ប្រការ ២ .-**

ការបង្វិលសងវិញអាចធ្វើឡើងចំពោះ ពន្ធ និងអាករនានា ដែលបានបង់នាពេលនាំចូលលើសម្ភារៈវត្ថុធាតុដើម ដែលបានប្រើប្រាស់ដោយផ្ទាល់ក្នុងការផលិត ឬបង្កើតទំនិញនៅព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបាននាំចេញ ។

ការបង្វិលសងវិញដូចមានចែងក្នុងប្រការនេះ ត្រូវមានការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ទីចាត់ការគយ និងរដ្ឋាករ លើករណីដោយឡែកនីមួយៗ ។

**ប្រការ ៣ .-**

ការបង្វិលសងវិញដូចមានចែងក្នុងប្រការខាងលើ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

១. សំណើសុំបង្វិលសងវិញត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ ហើយដាក់ជូនទីចាត់ការគយ និងរដ្ឋាករ ដោយអមជាមួយនូវឯកសារយោងពាក់ព័ន្ធនានា រួមមានប្រតិវេទន៍គយ បង្កាន់ដៃពន្ធ អញ្ញត្តិប័ណ្ណ របាយការណ៍ត្រួតពិនិត្យទំនិញ វិញ្ញាបនប័ត្របំផ្លាញចោលដែលមានចុះហត្ថលេខាមន្ត្រីគយ ប្រតិវេទន៍នាំចេញ ដែលមានការបញ្ជាក់ពីគយ និងឯកសារថ្លៃកាត់ជាដើម ។

២. សំណើសុំបង្វិលសងវិញដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវធ្វើឡើងក្នុងរង្វង់ មួយ(១) ឆ្នាំ គិតចាប់ពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយនាំចូល ឬក្នុងរង្វង់ មួយ (១) ឆ្នាំគិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកដោះស្រាយការតវ៉ា ឬតុលាការមានសមត្ថកិច្ច ។

៣. សំណើសុំបង្វិលសងវិញដូចមានចែងក្នុងប្រការ ២ ខាងលើ ត្រូវធ្វើឡើងតែក្នុងលក្ខខណ្ឌ ដែលទំនិញផលិតចេញពីសម្ភារៈវត្ថុធាតុដើមនាំចូល ត្រូវបាននាំចេញក្នុងរង្វង់ មួយ (១) ឆ្នាំគិតចាប់ពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយនាំចូលនៃទំនិញជាសម្ភារៈវត្ថុធាតុដើមដែលបាននាំចូលដោយបង់ពន្ធ និងអាករ ហើយប្រើប្រាស់សម្រាប់ផលិតទំនិញនាំចេញនោះ ។

**ប្រការ ៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៥
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ១០៩......សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងទំនិញគ្មានការទាមទារ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ ១**.-

ត្រូវបានដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គយស្រប តាមបញ្ញត្តិមាត្រា ៥២ នៃច្បាប់ស្តីពីគយនូវទំនិញ គ្មានការទាមទារដូចតទៅនេះ៖

ទំនិញរក្សាទុកក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ឬនៅក្នុងកណ្តាគារគយមានដែនកំណត់ដែលហួសរយៈពេលកំណត់ក្រោមបញ្ញត្តិនៃប្រកាស

ស្តីពីសន្និធិគយបណ្តោះអាសន្ន ឬប្រកាសស្តីពីកណ្តាគារគយមានដែនកំណត់ ។

- ទំនិញដែលពុំត្រូវបានធ្វើប្រតិវេទន៍គយក្នុងរយៈពេលកំណត់ក្រោមបញ្ញត្តិនៃប្រកាសស្តីពីសន្និធិគយបណ្តោះអាសន្ន ។

- ទំនិញផ្ញើតាមប្រៃសណីយ៍ដែលគម្យជនបដិសេធមិនទទួលយក ឬគម្យជនពុំត្រូវបានរកឃើញ និងមិនអាចបញ្ជូនទំនិញត្រឡប់ទៅអ្នកផ្ញើវិញបាន ។

- ទំនិញ និងមធ្យោបាយដឹកជញ្ជូនពុំជាប់អយ័ត ដែលស្ថិតនៅក្នុងកន្លែងបញ្ចេញទំនិញពីគយ ហើយម្ចាស់បានបោះបង់ចោលជាលាយល័ក្ខណ៍អក្សរ ។

**ប្រការ ២.-**

ទំនិញគ្មានការទាមទារដែលស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គយ ត្រូវចុះក្នុងបញ្ជីនៃនិក្ខិត្តភ័ណ្ឌគយដោយឡែកមួយ ។ ទំនិញគ្មានការទាមទារដែលមានតម្លៃតិចជាង ពីររយពាន់ ( ២០០.០០០ ) រៀល អាចត្រូវបានចាត់ចែងតាមគម្យដ្ឋានណាមួយដោយ រដ្ឋបាលគយ ។

**ប្រការ ៣.-**

ប្រសិនបើម្ចាស់ទំនិញត្រូវបានស្គាល់ រដ្ឋបាលគយត្រូវជូនដំណឹងជាបន្ទាន់ ដល់ម្ចាស់ទំនិញគ្មានការទាមទារថា ទំនិញទាំងនោះនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈស្របតាមបញ្ញត្តិនៃប្រកាសនេះ កាលណាពុំមានការទាមទារក្នុងរយៈពេល ហុកសិប (៦០) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ ។

**ប្រការ ៤.-**

ក្នុងករណីពុំអាចរកម្ចាស់ឃើញ ឬពុំស្គាល់ម្ចាស់រដ្ឋបាលគយត្រូវចេញប្រវេសន៍សាធារណៈ ហើយបិទផ្សាយនៅការិយាល័យគយ ឬសាលាឃុំ - សង្កាត់ជិតបំផុតដើម្បីជាការជូនដំណឹងដល់ម្ចាស់ទំនិញ ។ ប្រវេសន៍នេះត្រូវមានចែងពី ៖

- បរិយាយមុខទំនិញ និងទីកន្លែងនៃទំនិញ
- កាលបរិច្ឆេទដែលទំនិញត្រូវបានចុះក្នុងបញ្ជីនៃនិក្ខិត្តភ័ណ្ឌគយ

- កាលបរិច្ឆេទដែលទំនិញអាចត្រូវបានចាត់ចែងតាមគម្រូដ្ឋាន បន្ទាប់ពីការដាក់លក់ដោយដេញថ្លៃជាសាធារណៈ ឬក្រោយរយៈពេល ហុកសិបថ្ងៃ (៦០) គិតពីថ្ងៃចេញប្រវេសន៍សាធារណៈ

- ការិយាល័យគយដែលទទួលខុសត្រូវគ្រប់គ្រង និងត្រួតពិនិត្យទំនិញ ដោយបញ្ជាក់នូវអាស័យដ្ឋានទំនាក់ទំនងលម្អិត ។

**ប្រការ ៥**.-

ការចំណាយនានាដែលកើតមានក្នុងពេលដែលទំនិញគ្មានការទាមទារស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គយជាបន្ទុករបស់ម្ចាស់ទំនិញ ។

**ប្រការ ៦**.-

មន្ត្រីគយអាចបើក ឬត្រួតពិនិត្យទំនិញគ្មានការទាមទារស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គយ តែពេលមានវត្តមានរបស់ម្ចាស់ទំនិញ ។ ក្នុងករណីដែលម្ចាស់ទំនិញអវត្តមាន ការត្រួតពិនិត្យនេះត្រូវមានវត្តមានរបស់បុគ្គលដែលត្រូវបានចាត់តាំងដោយតុលាការមានសមត្ថកិច្ចតាមសំណើរបស់រដ្ឋបាលគយ។

**ប្រការ ៧**.-

ក្រោយរយៈពេល ហុកសិបថ្ងៃ (៦០) គិតពីថ្ងៃចេញប្រវេសន៍សាធារណៈខាងលើ ម្ចាស់ទំនិញត្រូវធ្វើការទាមទារទំនិញរបស់ខ្លួន ។ ប្រសិនបើហួសរយៈពេលនេះ ទំនិញនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈ ស្របតាមបញ្ញត្តិនៃប្រកាសនេះ ។

រដ្ឋបាលគយត្រូវទទួលខុសត្រូវរៀបចំចាត់ចែងការដាក់លក់ដោយដេញថ្លៃជាសាធារណៈនូវទំនិញគ្មានការទាមទារ ស្របតាមនីតិវិធីជាធរមានដល់អ្នកដេញថ្លៃដែលហ៊ានឱ្យថ្លៃខ្ពស់បំផុត ។ ទំនិញគ្មានការទាមទារដែលបានដាក់លក់ពុំត្រូវជាប់បន្ទុកពន្ធ និងអាករនាំចូលឡើយ ។ អ្នកដេញថ្លៃបានមានសិទ្ធិប្រើប្រាស់ទំនិញទាំងនេះស្របតាមបញ្ញត្តិនៃច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

